# ជ័យជំនះ និង ការរលះកម្លាំង

## La victoire et l’épuisement

គណបសង្គ្រោះជាតិ មានជំនឿជាក់ច្បាស់ថា ខ្លួនមានជ័យជំនះនយោបាយ លើគណបក្សប្រជាជន ក្នុងអាណត្តិ ទី៥ ចូលក្នុងរដ្ឋសភា ដើរតួជា គណបក្សប្រឆាំង។ បើយោងតាម ចំនួនអាសនៈ និង ចំនួន គណកម្មការ នៃ រដ្ឋសភា ដែលខ្លួន ជា អ្នកដឹកនាំ យើងអាចទុកជាជ័យជំនះពិតប្រាកដ របស់គណបក្សសង្គ្រោះជាតិ នៅក្នុង គ្រោងលទ្ធិប្រជាធិបតេយ្យ។ តែយើងដឹងច្បាស់ថា នៅស្រុកខ្មែរ ជាស្រុក គ្មាននីតិរដ្ឋ គ្មានលទ្ធិប្រជាធិបតេយ្យ ដូច្នេះ លើកយកតួនាទីជា គណបក្សប្រឆាំង មកថ្លៃថ្លា ដល់រដ្ឋសភា បច្ចុប្បន្ន ថា ជា រដ្ឋសភាជាតិ មាន អំណាច នីតិបញ្ញាតិ ពិតប្រាកដ សំរាប់គ្រាន់តែ ធ្វើយុត្តិកម្ម នូវ វត្តមានខ្លួន ជាអ្នកឈ្នះនយោបាយមួយដែរ នៅក្នុង រដ្ឋសភា គឺជា **ការសម្រើបបញ្ញា**[1] ចោលតែប៉ុណ្ណោះ។

តាមការពិត គណបក្សសង្គ្រោះជាតិ កំពុងតែយក ភាពមិនស្របច្បាប់ មកទុកជាច្បាប់ សំរាប់យកមកអនុវត្ត នៅក្នុងស្រុខ្មែរ ដែល ជាច្បាប់ រំលាយ លទ្ធិប្រជាធិបតេយ្យ។ «ភាពមិនស្រប**ច្បាប់មកទុកជាច្បាប់**[2]» នេះ វាក្លាយ ជា **នីតិសា**[3] សំរាប់គ្រប់ការបោះឆ្នោត នៅថ្ងៃមុខ គឺនាំគ្នាបោះឆ្នោត គ្មានសេរី គ្មានយុត្តិធម៌ ហើយនៅទីបញ្ចប់ គូប្រជែង នាំគ្នាស្រុះស្រួលគ្នាដើម្បី ចែកឈ្នះគ្នា ឬ ចែកអំណាចគ្នា បោះបង់ចោល នូវឆន្ទះ ម្ចាស់ឆ្នោត គ្មានអៀនខ្មាស់នោះឡើយ។ តែការចែកគ្នាឈ្នះ នោះទៀត គឺធ្វើឲមានរូបភាព ជាទង្វើ បង្គ្រប់កិច្ច ព្រោះការពិត គឺ សំរាប់តែ គណបក្សកាន់អំណាច រក្សា **អាជ្ញាសិទ្ធិ**[4] តែប៉ុណ្ណោះ។ ម្យ៉ាងមួយទៀត អ្នកដឹកនាំគណបក្ស ជាភាគីក្នុងការចរចារ គេធ្វើដោយសម្ងាត់បំផុត ក្នុងរង់តូចបំផុត ដើម្បី អ្នកខ្លាំង ងាយស្រួល ចែកម្រែ ដល់ អ្នកខ្សោយ ជាលុយក្តី ជាសម្បត្តិធម្មជាតិក្តី។ ការទទួលកម្រែនេះឯង ដែលនាំឲ អ្នកទទួលផល តម្រូវឲ ពួកគេ ប្រតិបត្តិ កិច្ចព្រមព្រាង ជា **តុណ្ហី**[5] មិនឲខុសសោះ ពុំនោះទេ ត្រូវអាជ្ញាធរ ចោទប្រកាន់ គ្រប់បែបយ៉ាង អាចនឹង ទទួល ទណ្ឌកម្ម ក្នុងបទឧក្រិដ្ឋ និង អាច កេណ្ឌយក ទ្រព្យសម្បត្តិ ថែមទៀត ដែលមានតុលាការ រណបអំណាច ជាអ្នកវិនិច្ឆ័យ។ ឧទាហរណ៍មានស្រាប់ គឺ ករណី សមាជិក គណបក្សសង្គ្រោះជាតិ មួយក្រុម ក្នុងនោះមានទាំងតំណាងរាស្ត្រ ផង។ ពួកអ្នកកាន់អំណាច គេចង់បង្ហោះសារដល់ លោក សម-រង្ស៊ី និង កែម-សុខា និង តំណាងរាស្ត្រ ឯទៀតៗ ដែលបាទជាប់ចោទ ហើយ រស់នៅក្រៅឃុំ ដែលបានទទួលកម្រែពីគេ ឲប្រយ័ត្នខ្លួន។ ហេតុនេះឯង បាន លោកទាំងពីរមិនហ៊ានតវ៉ា ជាផ្លូវការ ការពារ ភឿនខ្លួន ដែលកំពុង ជាប់ ពន្ធនាគារ នោះទេ។ ម្នាក់ៗ រស់យកតែរួចខ្លួន ហើយថែមទាំងគំរាបកំហែង ដាក់គ្នាទៅវិញទៅមក កុំអោយប្រកែកឲសោះ និង ប្រឆាំងនឹង គ្រប់អនុសាសន៍ របស់ សម្តេច ហ៊ុន-សែន ព្រោះនឹងនាំ ទុក្ខដល់អ្នកដទៃ។ ហើយបើចង់បានអ្វីមួយ ត្រូវស្នើរសូម ដោយត្រង់ទៅ សម្តេច ប្រធាន ហេង-សំរិន ដែល លោក សម-រង្ស៊ី និង កែម-សុខា គោរពប្រតិបត្តិ ដូចជាព្រះបីតា។

ជ័យជំនះ ជាការស្រមៃ របស់ ថ្នាក់ដឹកនាំ គណបក្សសង្គ្រោះជាតិ នេះ ជា ការរលះកម្លាំងចិត្តប្រជាពលរដ្ឋខ្មែរ ដែលនឹងស្មានថា អាណត្តិ ទី៥ ជាពន្លឺ នៃ សេរីភាព និង លទ្ធិប្រជាធិបតេយ្យ ដែលជា ដង្ហើមជាតិ។

២២ មករា ឆ្នាំ ២០១៥

ឧប សៅ សង្ហា

---

[1] ការសម្រើបបញ្ញា= masturbation intellectuelle។

[2] ភាពមិនស្របច្បាប់ មកទុកជាច្បាប់= Constitutionnaliser l’anti constitution។

[3] និតិសា= jurisprudence។

[4] អាជ្ញាសិទ្ធិ= Pouvoir absolu។

[5] តុណ្ហី= tacite ; ដោយស្ងាត់ស្ងៀម។